# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តសៀមរាប**

សំណុំរឿងព្រហ្មទណ្ឌលេខៈ១០៦៨
ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០១៨
សំណុំរឿងជំនុំជំរះលេខៈ ៣០១
ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨
សាលក្រមលេខៈ **៨៣ "គ"**
ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ ២០១៩

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាសាធារណៈ នៅនាទីសាលាដំបូងខេត្តសៀមរាបសាលសវនាការលេខ២B

កាលបរិច្ឆេទបើកសវនាការៈនៅថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៩ វេលា ព្រឹក

កាលបរិច្ឆេទប្រកាសសាលក្រមៈ នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១៩ វេលារសៀល

## ចៅក្រមជំនុំជម្រះ

លោក [redacted] ឋានៈចៅក្រមសាលាដំបូងខេត្តសៀមរាប

## តំណាងអយ្យការ

លោក [redacted] ឋានៈព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តសៀមរាប

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ឋានៈក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ ១០៦៨ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទៈ

១.ឈ្មោះ [redacted] រ៉ាដ្ឋ ភេទប្រុស អាយុ ២៣ឆ្នាំ សញ្ជាតិខ្មែរ មុខរបរបើករថយន្តក្រុង សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តសៀមរាប កំរិតវប្បធម៌ថ្នាក់ទី៧ ទីលំនៅបច្ចុប្បន្នភូមិ [redacted] ក្រុងសៀមរាប ខេត្តសៀមរាប ប្រពន្ធឈ្មោះ [redacted] ស្រីអូន កូនគ្មាន ឪពុកឈ្មោះ [redacted] រ៉ាឌី "រ" ម្តាយឈ្មោះ [redacted] ហួរ "រ" នៅលើវ ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

**ឃុំខ្លួនតាមដីកាលេខ ១១៩០ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៨។**

ត្រូវជាប់ចោទពីបទៈ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅ ភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា ៤០ **កថាខណ្ឌ៣ និងកថាខណ្ឌ៤** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.ឈ្មោះ [redacted] សុភា ភេទប្រុស អាយុ ៣៤ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកសិកម្ម សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅ រាជធានីភ្នំពេញ កំរិតវប្បធម៌ថ្នាក់ទី៩ ទីលំនៅបច្ចុប្ប[redacted] ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] វណ្ណណុល "រ" ម្តាយឈ្មោះ [redacted] ថន "រ" នៅលើវ ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

**ឃុំខ្លួនតាមដីកាលេខ ១១៩១ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៨។**

Scanned with CamScanner

៣.ឈ្មោះ [redacted] រ៉ា ភេទប្រុស អាយុ ១៨ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករថយន្តក្រុង សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅ រាជធានីភ្នំពេញ កំរិតវប្បធម៌ថ្នាក់ទី៩ ទីលំនៅបច្ចុប្បន្ន [redacted] សៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] បញ្ញា "រ" ម្តាយឈ្មោះ [redacted] ហ៊ាន "រ" នៅលីវ ទោសពីមុនគ្មាន ។ (ក្រៅឃុំបណ្តោះអាសន្ន)

៤.ឈ្មោះ [redacted] សាក់ ភេទប្រុស អាយុ ២១ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរសន្តិសុខ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប កំរិតវប្បធម៌ថ្នាក់ទី៧ ទីលំនៅបច្ចុប្បន្នភូមិទ្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] បូរី "រ" ម្តាយឈ្មោះ វ៉ាន់ រ៉ាក់ "រ" នៅលីវ ទោសពីមុនគ្មាន ។ (ក្រៅឃុំបណ្តោះអាសន្ន)

៥.ឈ្មោះ [redacted] ពុទ្ធាវង្ស ភេទប្រុស អាយុ ៣៣ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរបើករថយន្តក្រុង សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តបាត់ដំបង កំរិតវប្បធម៌ថ្នាក់ទី៩ ទីលំនៅបច្ចុប្បន្នភូមិវាល សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] សារ៉េត "ស" ម្តាយឈ្មោះ [redacted] សារ៉េត "ស" ប្រពន្ធឈ្មោះ [redacted] កាលី មានកូន១នាក់ ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

**ឃុំខ្លួនតាមដីកាលេខ ១១៩៥ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៨។**

៦.ឈ្មោះ [redacted] តុន ភេទប្រុស អាយុ ២៦ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរបើករថយន្តក្រុង សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅរាជធានីភ្នំពេញ កំរិតវប្បធម៌ថ្នាក់ទី៩ ទីលំនៅបច្ចុប្បន្នភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] វឿន "ស" ម្តាយឈ្មោះ [redacted] យៀង "ស" ប្រពន្ធឈ្មោះ [redacted] ធវី គ្មានកូន ទោសពីមុនគ្មាន ។ (ក្រៅឃុំបណ្តោះអាសន្ន)

៧.ឈ្មោះ [redacted] តុនពីន ភេទប្រុស អាយុ ២៥ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករលើកមាន់ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូ [redacted] ខេត្តកំពង់ចាម កំរិតវប្បធម៌ថ្នាក់ទី៧ ទីលំនៅបច្ចុប្បន្នភូមិគោកដូង សង្កាត់ទឹកវិល ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] ប៉ោលីម "រ" ម្តាយឈ្មោះ [redacted] ស្រីញ៉ "រ" ប្រពន្ធឈ្មោះ [redacted] ស្រស់ ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

**ឃុំខ្លួនតាមដីកាលេខ ១១៩៦ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៨។**

៨.ឈ្មោះ [redacted] សុភាព ភេទប្រុស អាយុ ៣៣ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរបើកបររថយន្ត សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពត កំរិតវប្បធម៌ថ្នាក់ទី៤ ទីលំនៅបច្ចុប្បន្នភូមិលាងគ្រើល ឃុំលាងគ្រើល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] មុំ "រ" ប្រពន្ធឈ្មោះ អារី ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

**ឃុំខ្លួនតាមដីកាលេខ ១១៩៧ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៨។**

៩.ឈ្មោះ [redacted] ហៀង ភេទប្រុស អាយុ ២៥ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរសន្តិសុខ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តព្រៃវែង កំរិតវប្បធម៌គ្មាន ទីលំនៅបច្ចុប្បន្នភូមិកសិកម្ម សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] គយ "ស" ម្តាយឈ្មោះ [redacted] វ័ល្ល "ស" ទោសពីមុនគ្មាន ។ (ក្នុងឃុំ)

**ឃុំខ្លួនតាមដីកាលេខ ១១៩៨ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៨។**

ត្រូវជាប់ចោទពីបទ: **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅ ភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា ៤២ កថាខណ្ឌ១ និងកថាខណ្ឌ២ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុភា និងឈ្មោះ [redacted] សុភាព ។

មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] តុន និងឈ្មោះ [redacted] វ៉ា ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ១៩៥ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩ ។

-បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១១៦៣ ចុះថ្ងៃទី០៧ ខែ មីនា ឆ្នាំ ២០១៩ ។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៤៨៩ ពស.ព្រជ(ក) ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ ២០១៩ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

## អង្គហេតុកើតមានឡើងដូចតទៅ៖

កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ នៅវេលាម៉ោង០៨ និង៣០នាទី កម្លាំងការិយាល័យបទល្មើសគ្រឿងញៀន នៃកងរាជអាវុធហត្ថខេត្តសៀមរាប បានចុះបង្ក្រាបបទល្មើសគ្រឿងញៀន នៅចំណុចភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ដោយធ្វើការឃាត់ខ្លួនបានឈ្មោះ រឿម វ៉ាដ្ឋ ភេទប្រុស ដកហូតបានម្សៅគ្រឿមពណ៌សថ្លា ចំនួន ៨កញ្ចប់តូច ទំងន់ ៤,៣២ក្រាម និងបានសារភាពថា កាលពីថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០១៨ មានអ្នកតេទៅទិញពីឈ្មោះ [redacted] វ៉ាដ្ឋ ជាច្រើននាក់ ក្នុងនោះមានឈ្មោះ [redacted] សុភា ភេទប្រុស បានតេទូរស័ព្ទទៅទិញពីឈ្មោះ រឿម វ៉ាដ្ឋ ព្រមទាំងដកហូតបានម្សៅគ្រឿងពណ៌សថ្លាចំនួន១កញ្ចប់ ទម្ងន់០,៣៣ក្រាម ហើយមានឈ្មោះ [redacted] វ៉ា,ឈ្មោះ [redacted] សាក់,ឈ្មោះ [redacted] ពុទ្ធាវង្ស ,ឈ្មោះ [redacted] តុន,ឈ្មោះ [redacted] តុនពីន,ឈ្មោះ [redacted] សុភាព និងឈ្មោះ [redacted] ហៀង ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] វ៉ាដ្ឋ បានឆ្លើយថា ខ្ញុំទទួលស្គាល់អង្គហេតុចោទប្រកាន់ ខ្ញុំពិតជួញដូរថ្នាំញៀន ខ្ញុំរកស៊ីជួញដូរបានរយៈពេល៣ខែហើយ ខ្ញុំដឹងថាជាអំពើខុសច្បាប់ ខ្ញុំយកមករំលែកលក់ចំនេញពី ៣០ ដុល្លា ទៅ៤០ដុល្លាអាមេរិក ។ ខ្ញុំមិនធ្លាប់មានទោសពីមុនទេ ។

-ជនជាប់ចោទឈ្មោះ [redacted] សុភា បានឆ្លើយថា ខ្ញុំទទួលស្គាល់បទចោទប្រកាន់ ខ្ញុំទើបតែប្រើប្រាស់លើកទី១ ខ្ញុំដឹងកំហុសហើយ ។

-ជនជាប់ចោទឈ្មោះ [redacted] ពុទ្ធាវង្ស បានឆ្លើយថា ខ្ញុំទទួលស្គាល់បទចោទប្រកាន់ ខ្ញុំចេះប្រើប្រាស់មូលហេតុបើកឡានពេលយប់ទៅភ្នំពេញ ។

-ជនជាប់ចោទឈ្មោះ [redacted] តុងពីន បានឆ្លើយថា ខ្ញុំទទួលស្គាល់បទចោទប្រកាន់ ខ្ញុំចេះប្រើប្រាស់តាមមិត្តភក្តិ ។

-ជនជាប់ចោទឈ្មោះ [redacted] សុភាព បានឆ្លើយថា ខ្ញុំទទួលស្គាល់បទចោទប្រកាន់ ខ្ញុំប្រើប្រាស់បានចំនួន ២លើក ចង់ដឹងនឹងសាកល្បង ។

-ជនជាប់ចោទឈ្មោះ [redacted] ហៀង បានឆ្លើយថា ខ្ញុំទទួលស្គាល់បទចោទប្រកាន់ ខ្ញុំជាសន្តិសុខយាម ខ្ញុំប្រើប្រាស់ថ្នាំញៀនព្រោះកុំឱ្យងងុយដេក ។

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] វ៉ា ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០១៨ នៅចំពោះមុខចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប ។

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] សាក់ ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០១៨ នៅចំពោះមុខចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប ។

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] តុន ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០១៨ នៅចំពោះមុខចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប ។

-អំណានរបាយការណ៍សំយោគលេខ៖ ១៦១ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១៨ របស់ការិយាល័យបទល្មើសប្រឆាំងគ្រឿងញៀន នៃកងរាជអាវុធហត្ថខេត្តសៀមរាប ។

+តុលាការប្រកាសបញ្ចប់ការសួរដេញដោល

-តំណាងអយ្យការសន្និដ្ឋានថា ឆ្លងតាមការសួរដេញដោលនាពេលសវនាការនេះ ឃើញថាជនជាប់ចោទបានឆ្លើយសារភាព ពិតបានប្រព្រឹត្តដូចអង្គហេតុចោទប្រកាន់ ហេតុនេះតំណាងអយ្យការសម្រេចតំកល់លើការចោទប្រកាន់ លើជនជាប់ចោទដដែល និងស្នើសុំតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុភា និងឈ្មោះ [redacted] សុភាព ឆ្លងតាមសវនាការនេះ ឃើញថាឈ្មោះ [redacted] សុភា និងឈ្មោះហាវ សុភាព បានឆ្លើយសារភាព និងដឹងកំហុសរបស់ខ្លួន ហេតុនេះសុំតុលាការផ្តល់ស្ថានសម្រាល ។

-ជនជាប់ចោទឈ្មោះ [redacted] រ៉ាដូ បានសំណូមពរថា៖ សុំតុលាការបន្ធូបន្ថយទោស ខ្ញុំដឹងកំហុស និងរាងចាលហើយ ។

-ជនជាប់ចោទឈ្មោះ [redacted] សុភា បានសំណូមពរថា៖ សុំតុលាការបន្ធូបន្ថយទោស ខ្ញុំដឹងកំហុស និងរាងចាលហើយ ។

-ជនជាប់ចោទឈ្មោះ [redacted] ពុទ្ធារង្សី បានសំណូមពរថា៖ សុំតុលាការបន្ធូបន្ថយទោស ខ្ញុំដឹងកំហុស និងរាងចាលហើយ ។

-ជនជាប់ចោទឈ្មោះ [redacted] តុងពីន បានសំណូមពរថា៖ សុំតុលាការបន្ធូបន្ថយទោស ខ្ញុំដឹងកំហុស និងរាងចាលហើយ ។

-ជនជាប់ចោទឈ្មោះ [redacted] សុភាព បានសំណូមពរថា៖ សុំតុលាការបន្ធូបន្ថយទោស ខ្ញុំដឹងកំហុស និងរាងចាលហើយ ។

-ជនជាប់ចោទឈ្មោះ [redacted] ហៀង បានសំណូមពរថា៖ សុំតុលាការបន្ធូបន្ថយទោស ខ្ញុំដឹងកំហុស និងរាងចាលហើយ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន និងប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំណូមពររបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារនានា របស់មន្ត្រីនគរបាលយុត្តិធម៌

-ក្រោយពីបានពិចារណា ត្រឹមត្រូវតាមច្បាប់ហើយ ។

**សាលាដំបូងខេត្តសៀមរាប**

**យល់ឃើញថា**

-ចម្លើយជនជាប់ចោទឈ្មោះ [redacted] **វ៉ាន់ឌី** បានឆ្លើយសារភាព ពិតបានយកថ្នាំញៀនមកលក់បន្ត និងវ៉ែលកលក់បន្ត ហើយត្រូវសមត្ថកិច្ចចាប់ខ្លួនដកហូតថ្នាំញៀនចំនួន ៥កញ្ចប់ ជាចម្លើយត្រឹមត្រូវ ស៊ីសង្វាក់ វត្ថុតាងដែលបានដកហូត និងរបាយការណ៍ស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ។

-ចម្លើយជនជាប់ចោទឈ្មោះ [redacted] សុភា,ឈ្មោះ [redacted] វ៉ា,ឈ្មោះ [redacted] សាក់,ឈ្មោះ [redacted] ពុទ្ធាវង្ស ,ឈ្មោះ [redacted] តុន,ឈ្មោះ [redacted] តុនពីន,ឈ្មោះ [redacted] សុភាព និងឈ្មោះ [redacted] ហៀង បានទទួលស្គាល់ធ្លាប់តែទិញថ្នាំញៀនពីឈ្មោះ [redacted] វ៉ាន់ឌី ជាចម្លើយត្រឹមត្រូវ ស៊ីសង្វាក់ វត្ថុតាងដែលបានដកហូត និងរបាយការណ៍ស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ។

-ចម្លើយរបស់ជនជាប់ចោទ, វត្ថុតាងដែលបានដកហូត និងរបាយការណ៏ស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ជាភស្តុតាងដាក់បន្ទុកដែលមានលក្ខណៈ គ្រប់គ្រាន់ និងស៊ីសង្វាក់គ្នាអាចកំណត់បានថា កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ នៅវេលាម៉ោង០៨ និង៣០នាទី កម្លាំងការិយាល័យបទល្មើសគ្រឿងញៀន នៃកងរាជអាវុធហត្ថខេត្តសៀមរាប បានចុះបង្ក្រាបបទល្មើសគ្រឿងញៀន នៅចំណុចភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ដោយធ្វើការឃាត់ខ្លួនបានឈ្មោះ [redacted] វ៉ាន់ឌី ភេទប្រុស ដកហូតបានម៉្សៅគ្រឿមពណ៌សថ្លា ចំនួន ៥កញ្ចប់តូច ទំងន់ ៤,៣២ក្រាម និងបានសារភាពថា កាលពីថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០១៨ មានអ្នកតែទៅទិញពីឈ្មោះ [redacted] វ៉ាន់ឌី ជាច្រើននាក់ ក្នុងនោះមានឈ្មោះ [redacted] សុភា ភេទប្រុស បានតេទូរស័ព្ទទៅទិញពីឈ្មោះ [redacted] វ៉ាន់ឌី ព្រមទាំងដកហូតបានម៉្សៅគ្រឿងពណ៌សថ្លាចំនួន ១កញ្ចប់ ទម្ងន់០,៣៣ក្រាម ហើយមានឈ្មោះ [redacted] វ៉ា,ឈ្មោះ [redacted] សាក់,ឈ្មោះ [redacted] ពុទ្ធាវង្ស,ឈ្មោះ [redacted] តុន,ឈ្មោះ [redacted] តុនពីន,ឈ្មោះ [redacted] សុភាព និងឈ្មោះ [redacted] ហៀង ។

-អំពើប្រព្រឹត្តរបស់ឈ្មោះ [redacted] វ៉ាន់ឌី បានទិញថ្នាំញៀនយកទៅលក់បន្តឱ្យអ្នកដទៃ យកផលចំណេញ និងត្រូវសមត្ថកិច្ចចាប់ខ្លួនព្រមទាំងវត្ថុតាង គឺជាការប្រព្រឹត្តល្មើសដោយចេតនា នូវបទល្មើសព្រហ្មទណ្ឌ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដូចមានចែងនិងផ្តន្ទាទោសតាមមាត្រា **៤០ កថាខណ្ឌ៣ កថាខណ្ឌ៤** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-អំពើប្រព្រឹត្តរបស់ឈ្មោះ [redacted] សុភា,ឈ្មោះ [redacted] វ៉ា,ឈ្មោះ [redacted] សាក់,ឈ្មោះ [redacted] ពុទ្ធាវង្ស,ឈ្មោះ [redacted] តុន,ឈ្មោះ [redacted] តុនពីន,ឈ្មោះ [redacted] សុភាព និងឈ្មោះ [redacted] ហៀង បានតេទូរស័ព្ទទាក់ទងទៅឈ្មោះ [redacted] វ៉ាន់ឌី ដើម្បីទិញថ្នាំញៀនយកទៅប្រើប្រាស់ គឺជាការប្រព្រឹត្តល្មើសដោយចេតនា នូវបទល្មើសព្រហ្មទណ្ឌ ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដូចមានចែងនិងផ្តន្ទាទោសតាមមាត្រា **៥២ កថាខណ្ឌ១ កថាខណ្ឌ២** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-មានពិរុទ្ធគ្រប់គ្រាន់លើឈ្មោះ [redacted] វ៉ាន់ឌី ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅ ភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា **៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-មានពិរុទ្ធគ្រប់គ្រាន់លើឈ្មោះ [redacted] សុភា,ឈ្មោះ [redacted] វ៉ា,ឈ្មោះ [redacted] សាក់,ឈ្មោះ [redacted] ពុទ្ធាវង្ស ,ឈ្មោះ [redacted] តុន,ឈ្មោះ [redacted] តុនពីន,ឈ្មោះ [redacted] សុភាព និងឈ្មោះ [redacted] ហៀង ពីបទ **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្ត

នៅ ភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០១៨ ។

បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា **៤២ កថាខណ្ឌ១ និងកថាខណ្ឌ២ និង មាត្រា ៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-វត្ថុចាប់យកមាន: ទូរស័ព្ទម៉ាក Samsung Galazy ពណ៌ស បែកកញ្ចក់ ចំនួន១គ្រឿង, ទូរស័ព្ទដៃម៉ាក HIYA ពណ៌ស លាយក្រហម ចំនួន១គ្រឿង,ទូរស័ព្ទដៃម៉ាក NOKIA ចុចពិល ពណ៌ក្រហម និងពណ៌ស្វាយ ចំនួន១ គ្រឿង,ស្រោមសំបុត្របិទជិតពណ៌ស មានស្នាមមេដៃរបស់ឈ្មោះ [redacted] រ៉ាដូ ចំនួន១កញ្ចប់ និងស្រោមសំបុត្រ បិទជិតពណ៌ស មានស្នាមមេដៃរបស់ឈ្មោះ [redacted] សុភា ចំនួន១កញ្ចប់ ពិតជាវត្ថុតាង ក្នុងអំពើល្មើស និង មធ្យោបាយ ក្នុងការទំនាក់ទំនងទិញថ្នាំញៀន គប្បីសំរេចរឹបអូស។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការនាពេលសវនាការ សន្និដ្ឋានចម្លើយរបស់ជនជាប់ចោទ បានសារភាពទាំងពីរនាក់ រួមទាំងភស្តុតាងដាក់បន្ទុក ស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុដូចការចោទប្រកាន់។ សុំ រក្សាការចោទប្រកាន់ទុកឲ្យតុលាការផ្តន្ទាទោសតាមច្បាប់ មានលក្ខណៈត្រឹមត្រូវតាមច្បាប់។

## ហេតុដូច្នេះសម្រេច

I-តុលាការរកឃើញថា: មានពិរុទ្ធភាពលើះ

១.ជនជាប់ចោទឈ្មោះ [redacted] **រ៉ាដូ** (មានសញ្ជាតិដូចខាងលើ)

ពីបទ: **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅ ភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យ ផ្តន្ទាទោស តាមមាត្រា**៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.ជនជាប់ចោទឈ្មោះ [redacted] **សុភា** (មានសញ្ជាតិដូចខាងលើ)

៣.ជនជាប់ចោទឈ្មោះ [redacted] **រ៉ា** (មានសញ្ជាតិដូចខាងលើ)

៤.ជនជាប់ចោទឈ្មោះ [redacted] **សាក់** (មានសញ្ជាតិដូចខាងលើ)

៥.ជនជាប់ចោទឈ្មោះ [redacted] **ពុទ្ធាចន្ទ្រ** (មានសញ្ជាតិដូចខាងលើ)

៦.ជនជាប់ចោទឈ្មោះ [redacted] **តុន** (មានសញ្ជាតិដូចខាងលើ)

៧.ជនជាប់ចោទឈ្មោះ [redacted] **តុនពីន** (មានសញ្ជាតិដូចខាងលើ)

៨.ជនជាប់ចោទឈ្មោះ [redacted] **សុភាព** (មានសញ្ជាតិដូចខាងលើ)

៩.ជនជាប់ចោទឈ្មោះ [redacted] **ហៀង** (មានសញ្ជាតិដូចខាងលើ)

ពីបទ: **ចាត់ចែងឱ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងបទប្រើប្រាស់ដោយខុសច្បាប់ នូវសារធាតុញៀន** ប្រព្រឹត្តនៅ ភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពី ថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា **៤២ កថាខណ្ឌ១ និងកថាខណ្ឌ២ និងមាត្រា ៤៥** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

II.ផ្តន្ទាទោសជនជាប់ចោទ:

១/ឈ្មោះ [redacted] **រ៉ាដូ** ដាក់ពន្ធនាគារកំណត់រយៈពេល **០២(ពីរ)ឆ្នាំ ០៦(ប្រាំមួយ)ខែ ។**

២/ឈ្មោះ [redacted] **សុភា** ដាក់ពន្ធនាគារកំណត់រយៈពេល **០២(ពីរ)ឆ្នាំ ០២(ពីរ)ខែ តែទោសនេះត្រូវអនុវត្តទោសព្យួររយៈពេល ១(មួយ) ឆ្នាំ ២(ពីរ)ខែ ។**

៣/ឈ្មោះ [redacted] **រ៉ា** ដាក់ពន្ធនាគារកំណត់រយៈពេល **០២(ពីរ)ឆ្នាំ ០២(ពីរ)ខែ ។**

៤/ឈ្មោះ [redacted] **សាក់** ដាក់ពន្ធនាគារកំណត់រយៈពេល **០២(ពីរ)ឆ្នាំ ០២(ពីរ)ខែ ។**

៥/ឈ្មោះ [redacted] **ពុទ្ធាវង្ស** ដាក់ពន្ធនាគារកំណត់រយៈពេល **០២(ពីរ)ឆ្នាំ ០២(ពីរ)ខែ ។**

៦/ឈ្មោះ [redacted] **គុន** ដាក់ពន្ធនាគារកំណត់រយៈពេល **០២(ពីរ)ឆ្នាំ ០២(ពីរ)ខែ ។**

៧/ឈ្មោះ [redacted] **គុងពីន** ដាក់ពន្ធនាគារកំណត់រយៈពេល **០២(ពីរ)ឆ្នាំ ០២(ពីរ)ខែ ។**

៨/ឈ្មោះ [redacted] **សុភាព** ដាក់ពន្ធនាគារកំណត់រយៈពេល **០២(ពីរ)ឆ្នាំ ០២(ពីរ)ខែ ។**

៩/ឈ្មោះ [redacted] **ហៀង** ដាក់ពន្ធនាគារកំណត់រយៈពេល **០២(ពីរ)ឆ្នាំ ០២(ពីរ)ខែ ។**

**III**-វត្ថុចាប់យកមាន: ទូរស័ព្ទម៉ាក Samsung Galazy ពណ៌ស បែកកញ្ចក់ ចំនួន១គ្រឿង, ទូរស័ព្ទដៃម៉ាក HIYA ពណ៌ស លាយក្រហម ចំនួន១គ្រឿង,ទូរស័ព្ទដៃម៉ាក NOKIA ចុចពិល ពណ៌ក្រហម និងពណ៌ស្វាយ ចំនួន១គ្រឿង,ស្រោមសំបុត្របិទជិតពណ៌ស មានស្នាមមេដៃរបស់ឈ្មោះ [redacted] រ៉ាដ្ឋ ចំនួន១កញ្ចប់ និងស្រោមសំបុត្របិទជិតពណ៌ស មានស្នាមមេដៃរបស់ឈ្មោះ [redacted] សុភា ចំនួន១កញ្ចប់ ត្រូវរឹបអូស។

តាមមាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**IV**-សាលក្រមនេះជំនុំជម្រះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៩ និងប្រកាសជាសាធារណៈ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **រ៉ាដ្ឋ**,ឈ្មោះ [redacted] **សុភា**,ឈ្មោះ [redacted] **ពុទ្ធាវង្ស**,ឈ្មោះ [redacted] **គុងពីន**,ឈ្មោះ [redacted] **សុភាព**,ឈ្មោះ [redacted] **ហៀង** និងកំបាំងមុខជនជាប់ចោទ **ឈ្មោះ [redacted] រ៉ា**,**ឈ្មោះ [redacted] សាក់ និង ឈ្មោះ [redacted] គុន ។**

-ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] |

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ១១កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

| បានឃើញ | ធ្វើនៅសៀមរាប ,ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩ |
|---|---|
| **ចៅក្រមជំនុំជម្រះ** | **ក្រឡាបញ្ជី** |
| [redacted] | [redacted] |



Scanned with CamScanner